**ស្ថានទូតអូស្ត្រាលី**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

<u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣

# អូស្ត្រាលីគាំទ្រគម្រោងកម្មវិធីដែលដឹកនាំដោយសហគមន៍មូលដ្ឋានទូទាំងប្រទេសកម្ពុជា

ថ្ងៃនេះ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសផ្តល់ជំនួយជាថវិកាចំនួន ៧,៩ លានដុល្លារអូស្ត្រាលី ដល់អង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលីចំនួន ២៦ ដែលធ្វើការក្នុងភាពជាដៃគូជាមួយអង្គការក្នុងស្រុកនានា ដើម្បីអនុវត្តនូវគម្រោងជួយដល់សហគមន៍ចំនួន ៤៩ តាមបណ្តាខេត្តទូទាំងប្រទេសកម្ពុជា។

ការប្រកាសនេះ ធ្វើឡើងដោយ លោក អនឌ្រីស សាប្រាក ឯកអគ្គរដ្ឋទូតរងអូស្ត្រាលីប្រចាំកម្ពុជា នៅក្នុងវេទិកាស្តីពី "កិច្ចពិគ្រោះយោបល់របស់អង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី-កម្ពុជា សម្រាប់ឆ្នាំ ២០២៣" ដល់អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិជាង ៧០ ស្ថាប័ន។

អស់រយៈពេលជិត ៥០ ឆ្នាំកន្លងមក កម្មវិធីសហប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី (ANCP) បានផ្តល់ជំនួយប្រចាំឆ្នាំដល់អង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលីនានា ដែលមានការទទួលស្គាល់ ក៏ដូចជាអង្គការដៃគូក្នុងស្រុកផងដែរ ដើម្បីអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព ដែលផ្តល់ប្រយោជន៍ផ្ទាល់ និងពិតប្រាកដដល់សហគមន៍។

ក្រៅពីការទទួលបានជំនួយរបស់កម្មវិធី ANCP ដៃគូអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលីនានា ក៏រកជំនួយពីសហគមន៍អូស្ត្រាលី និងជំនួយពីសាធារណៈ ក៏ដូចជាការរួមចំណែកដោយស្ម័គ្រចិត្តជួយដល់គម្រោងរបស់ពួកគេផងដែរ។

អង្គការដៃគូមួយចំនួនដែលទទួលបានជំនួយក្នុងឆ្នាំនេះ រួមមាន:

• អង្គការ APHEDA ដើម្បីលុបបំបាត់ជម្ងឺនានាបណ្តាលមកពីសារជាតិអាបេស្តុស និងការធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌការងារសម្រាប់បុគ្គលិកស្ត្រី
• អង្គការ ChildFund Australia ដើម្បីធ្វើអោយប្រសើរឡើងនូវលទ្ធផលសិក្សាសម្រាប់សាលាបឋមសិក្សាចំនួន ១១ ស្ថិតក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង
• អង្គការ CUFA ដើម្បីបង្កើនសមត្ថភាពសហគ្រិនរបស់អាជីវកម្មខ្នាតតូចជាង ៦០០
• មូលនិធិ Fred Hollows ផ្តល់ការវះកាត់ភ្នែកឡើងបាយ ឬការព្យាបាលជំងឺភ្នែកដល់អ្នកជំងឺប្រមាណជិត ១២០០ នាក់
• អង្គការ Marie Stopes International Australia ដើម្បីពង្រឹងសមត្ថភាពរបស់ដៃគូក្នុងស្រុកនានា ក្នុងការផ្តល់សេវាផែនការគ្រួសារ សេវាសុខភាពផ្លូវភេទ និងបន្តពូជ
• អង្គការ Plan International ដើម្បីពង្រីកសួនសិក្សារបស់ពួកគេបន្ថែមទៀតទៅដល់សាលាគោលដៅថ្មីចំនួន ៤១ កន្លែង
• អង្គការ Save the Children ដើម្បីកាត់បន្ថយឧប្បត្តិហេតុនៃអំពើហឹង្សាលើកុមារ និងស្ត្រី ដោយបង្កើនការចូលរួមពីបុរស
• អង្គការ Sight for All ដើម្បីគាំទ្រដល់ក្រុមគ្រូពេទ្យភ្នែកកម្ពុជាចំនួន ៤ នាក់ បន្តការសិក្សារយៈពេល ២ ឆ្នាំ ដើម្បីពង្រឹងសុខភាពភ្នែកនៅខេត្តតាកែវ និងរតនគិរី
• អង្គការ WaterAid ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត និងអនាម័យ សម្រាប់ជនមានពិការភាព និងស្ត្រីក្នុងខេត្តកំពង់ឆ្នាំង

លោក សាប្រាក បានមានប្រសាសន៍ថា "អូស្ត្រាលីផ្តល់តម្លៃខ្ពស់ចំពោះជំនាញ និងបណ្តាញនានារបស់អង្គការមិនមែនរដ្ឋាភិបាលទូទាំងប្រទេសកម្ពុជា ព្រមទាំងការរួមចំណែករបស់ពួកគេក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះ។ ក្នុងនាមជាផ្នែកមួយនៃសង្គមស៊ីវិល ពួកគេដើរតួយ៉ាងសំខាន់ក្នុងការបំពេញតួនាទីរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍ ជាពិសេសសម្រាប់សហគមន៍នៅតាមទីដាច់ស្រយាល និងងាយរងគ្រោះនានា»។

លោក សាប្រាក បានបន្ថែមថា "កិច្ចពិគ្រោះយោបល់ ជាផ្នែកមួយនៃកិច្ចពិភាក្សាជាបន្តបន្ទាប់ ដែលយើងនឹងអនុវត្តនៅប៉ុន្មានខែខាងមុខនេះ ដោយយើងបង្កើតផែនការភាពជាដៃគូអភិវឌ្ឍន៍ថ្មីមួយ ដើម្បីកំណត់ទិសដៅរយៈពេលវែងនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់យើងជាមួយប្រទេសកម្ពុជា។ យើងនឹងចូលរួមជាមួយរដ្ឋាភិបាលកម្ពុជា ស្ថាប័នអប់រំ ធុរជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកមតិយោបល់ និងទស្សនៈរបស់ពួកគេ។

កាលពីខែកន្លងទៅ រដ្ឋាភិបាលអូស្ត្រាលីបានចេញផ្សាយនូវគោលនយោបាយអភិវឌ្ឍន៍អន្តរជាតិថ្មីមួយ ដែលបានកំណត់ជាង ៣០ គោលដៅដែលត្រូវធ្វើ ដើម្បីផ្តល់នូវកម្មវិធីដែលមានប្រសិទ្ធភាព ឆ្លើយតបនឹងតម្រូវការ តម្លាភាព និងគណនេយ្យភាព។ គោលនយោបាយនេះ រួមបញ្ចូលទាំងវិធីសាស្ត្រក្នុងការពង្រឹងឡើងវិញនូវផែនការយុទ្ធសាស្ត្ររបស់ប្រទេស តាមរយៈផែនការភាពជាដៃគូអភិវឌ្ឍន៍ថ្មី។

ផែនការភាពជាដៃគូអភិវឌ្ឍន៍ គឺជាឱកាសមួយសម្រាប់ពួកយើងក្នុងការវាយតម្លៃ ស្តាប់ដៃគូនានារបស់យើង និងធ្វើការកំណត់ ដើម្បីធានាថាយើងកំពុងឆ្លើយតបទៅនឹងបញ្ហាធំៗនានាដែលយើងកំពុងប្រឈមនៅកម្ពុជា និងបង្កើនប្រសិទ្ធភាពនៃកម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍរបស់យើង។

ព័ត៌មានបន្ថែមអំពីកម្មវិធី ANCP មាននៅទីនេះ៖ https://www.dfat.gov.au/development/who-we-work-with/ngos/ancp/australian-ngo-cooperation-program

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au



កសិករដែលគាំទ្រដោយអង្គការទស្សនៈពិភពលោកអន្តរជាតិ កំពុងប្រមូលផលស្ពៃ នៅស្រុកស្អាង ខេត្តកណ្តាល។



និស្សិតគិលានុបដ្ឋាយិកាផ្នែកភ្នែកកំពុងពិនិត្យភ្នែក នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។